ភ្នំពេញ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣

# អនុក្រឹត្យលេខ ០៨ អនក្រ ស្តីពីឯកសណ្ឋាន និងផ្លាកសញ្ញា របស់នគរបាលជាតិកម្ពុជា

* * *

សហប្រធានរដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

- បានឃើញក្រឹត្យរបស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងសន្តិសុខជាតិ

## សំរេច

**មាត្រា ១** : ឯកសណ្ឋាននគរបាលជាតិកម្ពុជា ត្រូវបានកំណត់ដូចខាងក្រោម ៖

រូបភាព និង ខ្នាតឯកសណ្ឋាន

ក - ឯកសណ្ឋានថ្នាក់ឧត្តមសេនីយ ៖ មាន ៧ សំរាប់ គឺ ៖

១ - ឯកសណ្ឋានធំ លេខ ១ « កុដស » ៖

អាវកុដស កត្រង់ ខោខ្មៅឆ្នូតបៃតងពីរ ឬកកាស្កេតពណ៌ខ្មៅ សំរាប់ពាក់ក្នុងពិធីបុណ្យជាតិធំ ៗ និង ព្រះរាជពិធី ។

រូបភាព និង ម៉ូត

- អាវកុដស កត្រង់ កាត់រាងអាវធំ គ្មានផែកខ្នង ចុងកអាវទាំងសងខាងមានប៉ាក់រូបក្បាច់ ផ្កាស្រូវពណ៌មាស លើស្មាមានប៉ូល ហោប៉ៅបួន « ខាងលើពីរដេរប៉ះគំកណ្តាលមាន ចាប់ផ្នត់មួយ គំរបរាងស្លឹកពោធិខាងក្រោមពីរ ដេរបង្កប់មានគំរបរាងចតុកោណកែង » អាវដៃវែងលើផ្នែរបត់ដៃអាវ មានប៉ានក្រណាត់ពាត់មាស ទំហំ ០៨ ស.ម ឡើរមានរូបព្រះសង្ហារពណ៌មាស ចំនួន ០៧ នៅចុងដៃអាវមានឡេវបញ្ចោត បី រូបព្រះសង្ហារពណ៌មាស ។
- ខោជើងវែងចង្កេះគ្មានភ្លី នៅខាងក្រោយមានហោប៉ៅមួយដេរបង្កប់គ្មានគំរបហោ ប៉ៅចំហៀងពីរ ដេរបង្កប់តាមថ្នេរខោមានប៉ានឆ្នូតពីរពណ៌បៃតង ប៉ានទីមួយ ១ មាន ១ទឹង ០២ ស.ម ។

- មួកកាស្កេតខាងលើក្រណាត់កម្ពីពណ៌ខ្មៅជើង និង ក្បាំងមួកពណ៌ខ្មៅ ជើងមួកផ្នែក ខាងមុខមាន ប៉ាក់ក្បាច់ផ្កាភ្ញីពណ៌មាស នៅលើគែមក្បាំងមួក មានប៉ាក់ក្បាច់ផ្កាភ្ញី ទេសឌិន ពណ៌មាសជុំជើងមួក និង ពាក់រូបព្រះសង្ហារពណ៌មាសខ្នាតធំលើមុខមួក ។

- ខ្សែឥស្សរិយយសពណ៌មាសវេញចូលគ្នាបីខ្សែអមពីរ មានបន្ទោកម្ជុលពីរពណ៌មាស ពាក់លើស្មាស្តាំ។

- ខ្សែក្រវ៉ាត់ធំពណ៌មាសក្បាលរាងពងក្រពើ និង មានក្បូរក្បាច់ខាងក្នុងក្រវ៉ាត់លើអាវហើយព្យួរ ដាវខាងឆ្វេង ។

- ស្បែកជើង ស្បែកកខ្លីពណ៌ខ្មៅ ចងខ្សែ ស្រោមជើងខ្មៅ ស្រោមដៃស ។

២- ឯកសណ្ឋានធំ លេខ ២ " វ៉ារី " : សំរាប់ពាក់ក្នុងពិធីមិទ្ទិញបំពេញបេសកកម្មនៅ ប្រទេសក្រៅ ទទួលភ្ញៀវជាតិអន្តរ ជាតិអាវខោ និង មួកក្រណាត់តេហ្គាល ពណ៌ស ។

## រូបភាព និង ម៉ូត

- អាវកាត់រាងវ៉ារីមានផែកខ្នង កបើកប៉ូលស្មាមានហោប៉ៅបួនដេរប៉ះ " ហោប៉ៅលើពីរដេរ បត់ផ្នត់កណ្តាល មានគំរបរាងស្លឹកពោធិ ខាងក្រោមពីរ គំរបរាងចតុកោណកែង " អាវមាន ឡេវបួន រូបព្រះសង្ហារ ពណ៌មាសអាវដៃវែង ។

- ខោជើងវែងផ្នេរបង្កប់ ចង្កេះគគ្មានក្លឺ មានហោប៉ៅបួន " ខាងក្រោយពីរដេរបង្កប់គំរប រាងស្លឹកពោធិនៅចំហៀងពីរដេរបង្កប់តាមថ្នេរខោ " ។

- មួកកាស្កេតខាងលើក្រណាត់តេហ្គាលពណ៌ស ជើង និងក្បាំងមួកពណ៌ខ្មៅ ជើងមួកផ្នែក ខាងមុខ និង ចំហៀងប៉ាក់ក្បាច់ផ្កាភ្ញីពណ៌មាស នៅលើគែមក្បាំងមួក មានប៉ាក់ក្បាច់ផ្កាភ្ញី ទេសឌិនពណ៌មាស ជុំជើងមួក និង ពាក់រូបព្រះសង្ហារពណ៌មាស ខ្នាតធំលើមុខមួក ។

- អាវសឺមីក្នុងកខុបក្រណាត់តេតារុងពណ៌សពាក់នៅពេលរាត្រី នៅពេលថ្ងៃពណ៌កាគី អាវដៃវែង មានហោប៉ៅមួយ គ្មានគំរប កាត់ស្រុងវែងដាក់ក្នុងខោ ។

- ក្រវ៉ាត់ក ពណ៌ខ្មៅ ស្រោមដៃពណ៌ស ។

- ស្បែកជើង ស្បែកកខ្លីពណ៌ខ្មៅ ចងខ្សែ ស្រោមជើងពណ៌ខ្មៅ ។

- ខ្សែក្រវ៉ាត់ ពណ៌ស ក្បាលខ្សែក្រវ៉ាត់មានគួរស្រេវទ្រ រូបរាជសីហ៍ពណ៌មាស ។

- ខ្សែឥស្សរិយយសពណ៌មាស " ដូចខាងលើ " ។

ចំពោះនារី អាវដូចគ្នាខាងលើតែជីពចង្កេះ កអាវរាងនារី សំពត់ហ្សីបក្រោមក្បាលជង្គង់ ឆែកក្រោយ ។

៣ - ឯកសណ្ឋានលេខ ៣ " ស្ពិនស៊័រ " : សំរាប់បំពាក់ក្នុងពិធីសមោសរ ។

រូបភាព និង ម៉ូត :

- អាវស្ទីនស័រ ដៃវែង ម៉ូតស្នាកាត់ខើចត្រឹមចង្កេះ អាវមានខ្សែរបញ្ឈាតម្ខាងបីដាក់ បញ្ចិតផ្នែកក្រោមខាងមុខ និង នៅចុងដៃអាវ ដាក់ខ្សែរបញ្ឈាតម្ខាងបី រូបព្រះសង្ហារពណ៌ មាស ។

- អាវសឺមីក្នុងពណ៌ស មានក្បាច់នៅជើងខ្នង ករឹងពាក់ណេ ។

- ខោ ដូច ឯកសណ្ឋានធំលេខ ១ ។

៤ - ឯកសណ្ឋានការងារ លេខ ៤ " សាហារីដៃវែន " : សំរាប់ពាក់បំពេញការងារប្រចាំថ្ងៃ ។

រូបភាព និង ម៉ូត :

- អាវដៃខ្លីពណ៌កាគី កបើកហោជៅ ប៉ូរ " ខាងលើពីរដេរប៉ះគំរបរាងចតុកោណកែង ខាង ក្រោមពីរដេរ ឃោតមកក្រៅមានគំរបរាងចតុកោណកែង " ប៊ូតូស្នាខ្នងជីតក្លីពីរ គ្មានផែក ខ្សែរចម្មតាពណ៌កាគី នៅចង្កេះមានក្រវ៉ាត់ជាប់អាវទំហំ ០៦ ស.ម ក្បាលខ្សែក្រវ៉ាត់ពណ៌ មាសរាងពងក្រពើ មានរូបម្កុដ ព្រះខ័នមានពានទ្រ ។

- ខោ ជើងវែងក្រណាត់ពណ៌កាគី " ម៉ូតដូចឯកសណ្ឋានធំលេខ ២ " ។

- មួក ស្បែកជើង និង ស្រោមជើងពណ៌ខ្មៅ ។

ចំពោះនារី អាវកបើកជីពចង្កេះ តាមរាងនារី សំពត់ហ្សីប ក្រោមក្បាលជង្គង់ផែកក្រោយ ។

៥ - ឯកសណ្ឋានការងារលេខ ៥ " ដៃខ្លីពណ៌កាគី " : សំរាប់ពាក់បំពេញការងារប្រចាំថ្ងៃ ។

រូបភាព និង ម៉ូត :

- អាវដៃខ្លីកបើក ប៉ូលស្នា កាត់ស្រុងដាក់ក្នុងខោ ហោប៉ៅពីរដេរប៉ះនៅចំកណ្តាលដេរ បត់ផ្នត់មួយមានគំរបរាងស្លឹកពោធិ ខ្សែរចម្មតាពណ៌កាគី ។

- ខោជើងវែងពណ៌កាគី " ម៉ូតដូចឯកសណ្ឋានធំលេខ ២ " ។

- មួកកាស្កេតពណ៌ខ្មៅ ។

- ចំពោះនារីអាវដូចបុរស សំពត់ហ្សីបក្រោមក្បាលជង្គង់ផែកក្រោយ ឬ ខោ ។

៦ - ឯកសណ្ឋានការងារលេខ ៦ " ដៃវែងពណ៌កាគី " : សំរាប់ពាក់ដូចឯកសណ្ឋាន ការងារខាងលើ ។

រូបភាព និង ម៉ូត :

- អាវដៃវែងកឌុប ប៉ូលស្នា ហោប៉ៅពីរ " ដូចខាងលើ " កាត់ស្រុងដាក់ក្នុងខោ ។

- ខោ មួក ស្បែកជើង ដូចឯកសណ្ឋានការងារខាងលើ ។

៧ - ឯកសណ្ឋានការងារលេខ ៧ " ដៃវែងពណ៌ត្រែអ៊ី "

សំរាប់ពាក់ពេលចុះប្រតិបត្តិការ របស់នគរបាលជាតិគ្រប់ថ្នាក់ ខោ អាវ ត្រែអ៊ីក្រណាត់ លាត ពណ៌ស្លឹកឈើ មួកបេរេត៍ពណ៌ ខ្មៅពាក់រូប ព្រះសង្ហារពណ៌មាស ខ្ចាតតូចនៅលើ ចំហៀងខាង ខាងឆ្វេងមួក ។

ខ្សែក្រវ៉ាត់ធំ ពណ៌ត្រែអ៊ីសាំងទ្រ៊ុង ខ្សែក្រវ៉ាត់តូចពណ៌ត្រែអ៊ីក្បាលខ្សែក្រវ៉ាត់រូប រាជសីហ៍ ពណ៌មាស ស្បែកជើងឃ្មុបសំពត់ ឬ ស្បែកកវែងពណ៌ខ្មៅ ជើងខោបញ្ចូលក្នុង កស្បែកជើង ។

ខ - ឯកសណ្ឋានថ្នាក់វរៈសេនីយ៍ : មាន ៧ សំរាប់ ម៉ូតពណ៌ និងរបៀបប្រើប្រាស់ ដូចឧត្តមសេនីយ៍ដែរ តែថ្នាក់វរៈសេនីយមានចំណុចខុសគ្នា គឺ :

- ឯកសណ្ឋានធំលេខ ១ កត្រង់ ខោជើងវែងពណ៌ខ្មៅ មានប៉ានឆ្នូតពណ៌បៃតងពីរ ទទឹងឆ្នូតប្រវែង ១ ស.ម ។

- មួកកាស្កេតដូចមួកឧត្តមសេនីយ៍ តែលើជើងមួកមានខ្សែ សូតាសវេញបីផ្លុង ពណ៌មាស និង លើគែមក្បាំងមួកមានក្បាច់ផ្កាភ្ញីទេសឌិនពណ៌មាស ឃ្លាតពី ជើងមួក សងខាងប្រវែង ៤ ស.ម ។

គ - ឯកសណ្ឋានថ្នាក់អនុសេនីយ៍ : មាន ៧ សំរាប់ ម៉ូតពណ៌និងរបៀបប្រើប្រាស់ ដូចឯកសណ្ឋានថ្នាក់វរៈសេនីយដែរ តែមានចំណុចខុសគ្នា គឺ :

- ឯកសណ្ឋានធំលេខ ១ នៅចុងកអាវ ចុងដៃអាវគ្មានភ្ញី ។

- ខោជើងវែងពណ៌ខ្មៅ មានឆ្នូត ១ ពណ៌បៃតង ទទឹង ១ ស.ម ។

- មួកកាស្កេត រូបភាពដូចមួកវរៈសេនីយដែរ តែលើជើងមុខមួក មានខ្សែសូតាស វេញបីផ្លុង ពណ៌មាសនិង លើគែមក្បាំងមួកមានខ្សែកន្ទុយកណ្ដុរពណ៌មាស ។

ឃ - ឯកសណ្ឋានថ្នាក់នាយ នគរបាលរង : មានឯកសណ្ឋាន ៤ សំរាប់គឺ លេខ ២ លេខ ៥ លេខ ៦ លេខ ៧ ។ ម៉ូត និងពណ៌ដូចថ្នាក់អនុសេនីយ៍ដែរ ។ មួកកាស្កេតនាយនគរបាលរងថ្នាក់ ព្រិន្ទ បាល ខាងលើក្រណាត់ តែហ្គាលពណ៌ខ្មៅនៅជើង មួកមានសែសយសំប៉ែតមួយពណ៌មាសភ្ជាប់ដោយ ឡេវពីររូបព្រះសង្ហារពណ៌មាស ក្បាំង មួកពណ៌ខ្មៅលាត និង មានរូបព្រះសង្ហារពណ៌មាសខ្ចាត ធំដាក់ពីលើមុខមួក ។មួកកាស្កេត នាយនគរបាលរងថ្នាក់ពលបាល ដូចមួកថ្នាក់ព្រិន្ទបាលដែរ តែលើជើងមួក មានសែសយ សំប៉ែតពណ៌ប្រាក់ ។

កំណត់សំគាល់ : នគរបាលគ្រប់ថ្នាក់ ពេលជំនុំ និង ពេលពិធីបុណ្យបន្ទាប់បន្សំ ឯកសណ្ឋានការងារលេខ ៦ អាចប្រើជាជំនួស ឯកសណ្ឋានធំលេខ ២ ដោយគ្រាន់តែ បន្ថែមក្រវ៉ាត់

កពណ៌ ខ្មៅប៉ុណ្ណោះ ។

ង - ឯកសណ្ឋានថ្នាក់ពលនគរបាល មានឯកសណ្ឋាន ៤ សំរាប់ ដូចនាយនគរបាល រងដែរ ។ មួកកាស្កេត ខាងលើ ក្រណាត់តែហ្គាលពណ៌ខ្មៅ នៅជើងមួកមានខ្សែស្បែក សំប៉ែតពណ៌ខ្មៅ ភ្ជាប់ដោយ ឡេវពីរ រូបព្រះសង្ហារ ពណ៌មាស និង ពាក់រូបព្រះសង្ហារពណ៌ មាសខ្នាតធំលើមុខមួក ។

**មាត្រា ២ :** ឯកសណ្ឋានរបស់កងកិត្តិយស និង សណ្តាប់ធ្នាប់ចរាចរ :

ក - ឯកសណ្ឋានរបស់កងកិត្តិយស : សំលៀកបំពាក់សំរាប់ពិធីកិត្តិយសដូចឯក សណ្ឋានធំលេខ ២ មួកកាស្កេតពណ៌សស្បែកជើងកវែងពណ៌ខ្មៅជើងខោបញ្ចូលក្នុង កស្បែកជើង ក្រវាត់កពណ៌ខ្មៅខ្សែ ឥស្សរិយយសពណ៌មាស សាំងទូរ៉ុងធំពណ៌សហើយ មានខ្សែពាក់ ឆៀងផ្តក់ទៅលើស្មាឆ្វេង ស្រោមដៃពណ៌ស ។ ចំពោះកង ម៉ូតូត្រូវប្រើមួក កាស់ពណ៌ស ។

ខ - ឯកសណ្ឋាននគរបាលសណ្តាប់ធ្នាប់ចរាចរណ៍ :

- ឯកសណ្ឋានលេខ ១ - ២ - ៣ - ៤ ខោអាវម៉ូតក្រណាត់ និង របៀបប្រើប្រាស់ដូច នគរបាលទូទៅ ។ ចាប់ពីថ្នាក់នាយនគរបាលរងចុះ ចំពោះតែអ្នក ដែលមានភារកិច្ចធ្វើ ចរាចរ មានឯក សណ្ឋានបីសំរាប់ ឯកសណ្ឋានលេខ ២ លេខ ៥ លេខ ៦ ដូចឯកសណ្ឋាននគរបាលជាតិទូទៅដែរ ខុសតែចំពោះឯកសណ្ឋានលេខ ៥ លេខ ៦ អាវពណ៌ស៊ីផែឡេវរូតមានអណ្តាតគ្របសំរាប់ ដាក់ឡេវ បញ្ឆោតខោពណ៌ខៀវក្រម៉ៅមានជ៉ានឆ្នូត បួយពណ៌ខ្មៅតាមបណ្តោយថ្នេរខោទាំងសង ខាងអាវ កាតីប តម្រូវដង ខ្លួន " វាស់កាត់ " ពាក់មួកកាស្កេតពណ៌ខ្មៅ ។

-ចំពោះមួកសំរាប់ជិះម៉ូតូពាក់មួកកាស់ពណ៌ខ្មៅ ស្រោមដៃពណ៌សសាំងទូរ៉ុងធំ ពណ៌សស្បែក ជើងកវែងពណ៌ខ្មៅហើយបញ្ចូលជើងខោក្នុងកស្បែកជើង ខ្សែកញ្ចែពណ៌ សពាក់លើស្មាឆ្វេង ។

**មាត្រា ៣ :** ផ្លាកសញ្ញានគរបាលជាតិ ត្រូវបានរៀបចំដូចខាងក្រោមនេះ :

ក - រូបព្រះសង្ហារ :

រូបព្រះសង្ហារយកតាមសម័យសង្គមរាស្ត្រនិយម ធ្វើអំពីលោហធាតុពណ៌មាស សំរាប់ដាក់ លើមួកកាស្កេតមានទំហំកំពស់ ៧,៨ ស.ម ទទឹង ៦,៥ ស.ម សំរាប់ដាក់ លើមុខមួកបេរេតីទំហំកំពស់ ៥,៣ ស.ម ទទឹង ៤,៣ ស.ម ។

ខ- ផ្លាកសញ្ញានគរបាលជាតិ : មានបួនប្រភេទ គឺ ÷

១ - ផ្លាកសញ្ញាពាក់លើដៃអាវស្តាំ ចុះពីថ្នេរចំងាយ ៨ ស.ម មានរាងមូលអង្កត់ ផ្ចិតប្រវែង ៧,៧ ស.ម ដែលមានរឹមជុំវិញពណ៌ស ទទឹង ២ ម.ម នៅខាងលើមួយ ភាគបួន ពណ៌ខៀវសរសេរ អក្សរកាត់ នប កំពស់អក្សរ ១,២ ស.ម នៅខាងក្រោមមួយ ភាគបួនពណ៌ខៀវសរសេរអក្សរបារាំង ពណ៌ស ( POLICE ) កំពស់អក្សរ ០១ ស.ម នៅចំកណ្តាលមួយភាគពីរ ផ្ទៃពណ៌ក្រហមមាន ប្រាសាទអង្គរវត្តកំពូល ៣ ពណ៌ស កំពស់ប្រាសាទកណ្តាល ២ស.ម បាត ៣ស.ម ។

២ - ផ្លាកសញ្ញាពាក់លើដៃអាវឆ្វេងចុះពីថ្នេរចំងាយ ៥ ស.ម មានរាងកោងផ្ទៃ ពណ៌ទង់ជាតិ ទំហំបណ្តោយជ្រុងលើ ១០,៥ ស.ម បណ្តោយជ្រុងក្រោម ៧ ស.ម ទទឹង ២, ៥ ស. ម ដែលមានរឹមជុំវិញពណ៌សនៅកណ្តាលផ្ទៃពណ៌ក្រហមសរសេរអក្សរ " នគរបាលជាតិកម្ពុជា " ពណ៌ស កំពស់ ០,៨ ស.ម ។

៣ - ផ្លាកសញ្ញារូបរាជសីហ៍ : ធ្វើរាងជាមេដាយពាក់បន្តោកនៅឡេវហោប៉ៅអាវ ស្តាំរាងមូល បាតស្រួចមានអង្កត់ផ្ចិត ៦,៥ ស.ម មានផ្ទៃពណ៌ខៀវចាស់នៅចំកណ្តាល ផ្ទៃមានរូបរាជសីហ៍ ពណ៌មាស ពន្លឺពណ៌ផ្ទៃមេឃ មានស្បែកបន្តោកប្រវែង ៥ ស.ម ខាង ក្រោមរូបរាជសីហ៍មានសរសេរ អក្សរកាត់ " ន.ប.ជ.ក " ពណ៌សនៅជុំវិញ មានរូបកងចក្រពណ៌ស ។

៤ - ផ្លាកសញ្ញាសំគាល់ & ផ្លាកសញ្ញាសំគាល់នាយនគរបាលពីថ្នាក់អនុសេនីយ៍ឡើង ទៅមាន រាងមូល អង្កត់ផ្ចិតប្រវែង ៥,៣ ស.ម ធ្វើអំពីលោហធាតុផ្ទៃពណ៌ខៀវចាស់ រឹមជុំវិញពណ៌មាស រូបកងចក្រពណ៌ប្រាក់ នៅចំកណ្តាលមានរូបរាជសីហ៍ពណ៌ មាសមាន សរសេរអក្សរបារាំង " POLICE NATIONAL " នៅពីក្រោមរូបកង ចក្រពណ៌ស ដែលមានស្រោម ស្បែក ទទឹង ៨ ស.ម បណ្តោយ ១៦ ស.ម បិទបើក អាចដោះបានដាក់ភ្ជាប់ខ្សែ ក្រវាត់សំរាប់ប្រើនៅ ពេល ស្លៀកពាក់ ស៊ីវិល ។

៥ - ផ្លាកឈ្មោះ និង អត្តលេខ :

ធ្វើអំពីក្រណាត់ពណ៌ឯកសណ្ឋានដេរភ្ជាប់លើ ថ្នេរគំរបហោប៉ៅអាវខាងស្តាំ បណ្តោយ ១០,៥ ស.ម ទទឹង ៣ ស.ម សំរាប់ដាក់លើឯកសណ្ឋានការងារ ឈ្មោះ នៅជួរខាងលើកំពស់អក្សរ ០,៨ ស.ម លេខនៅជួរខាងក្រោមកំពស់ ០,៧ ស.ម អក្សរ និង លេខពណ៌ស ។

មាត្រា ៤ : ចំពោះសញ្ញាសំរាប់ប្រភេទកងកំលាំងជំនាញ និង ឯកសណ្ឋានអង្គរក្សត្រូវកំណត់ដោយ ប្រកាស ក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ ។

មាត្រា ៥ : រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងសន្តិសុខជាតិត្រូវ ទទួលបន្ទុក អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

**សហប្រធាន**

រដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា

ព្រះហស្តលេខា ហត្ថលេខា និង ត្រា

ស្ដេចក្រុមហ្លួង **នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * * *

# ២ - សេចក្ដីសំរេច

ភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៩៣

## សេចក្ដីសំរេចលេខ ២៨ សសរ ស្ដីពីមុខងារ និង ភារកិច្ចរបស់ ឯកឧត្តម ឧត្តមសេនីយ៍ សក់ ស៊ុតសាខន

រដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា

- បានឃើញក្រឹត្យស្ដីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា របស់សម្ដេចព្រះឧបយុវរាជ នរោត្តម សីហនុ ប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣
- បានឃើញក្រឹត្យរបស់សម្ដេចព្រះឧបយុវរាជ នរោត្តម សីហនុ ប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ៣ កក្កដា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង ឯកឧត្តម ឧត្តមសេនីយ៍ សក់ ស៊ុតសាខន ជាទីប្រឹក្សារបស់សហប្រធានរដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា ទទួលបន្ទុកកិច្ចការការពារជាតិ
- ផ្អែកតាមសភាពការណ៍ចាំបាច់នៃរាជការ

**សំរេច**

**មាត្រា ១ :** ឯកឧត្តម ឧត្តមសេនីយ៍ **សក់ ស៊ុតសាខន** ជាទីប្រឹក្សារបស់សហប្រធានរដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា ទទួលបន្ទុកកិច្ចការពារជាតិមានភារកិច្ចដូចតទៅ ៖

១ - ជួយ សហប្រធានរដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា ក្នុងវិស័យនយោបាយការពារជាតិ